# ស្វែងរក ទីតាំងចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលនៅជិតលោកអ្នក!

**ថ្នាំបង្ការជំងឺ COVID-19 គឺមានសម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែ ឡើងទៅ។**

- ថ្នាំបង្ការ គឺឥតគិតថ្លៃ។
- អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក នៅពេលដែលអ្នកទទួលចាក់ថ្នាំបង្ការឡើយ។
- អ្នកមិនចាំបាច់មានធានារ៉ាប់រងសុខភាព ដើម្បីទទួលចាក់ថ្នាំបង្ការឡើយ។
- អាចរកថ្នាំបង្ការបាននៅទីតាំងរាប់រយនៅទូទាំងខោនធី LA រួមមានដូចជា គ្លីនិក ឱសថស្ថាន ការិយាល័យគ្រូពេទ្យជំនាញខាងកុមារ សាលារៀន ទីកន្លែងគោរពបូជា សួនឧទ្យាន ស្ថានីយរថភ្លើងក្រោមដី និងទីកន្លែងជាច្រើនទៀត។
- នៅតាមទីកន្លែងជាច្រើន មិនចាំបាច់តម្រូវឱ្យធ្វើការណាត់ជួបទេ។

## វិធីងាយៗ 3 យ៉ាង ដើម្បីទទួលចាក់ថ្នាំបង្ការនៅក្នុងខោនធី LA៖



1. ចូលទៅកាន់គេហទំព័រ **ph.lacounty.gov/howtogetvaccinated** ហើយប្រើប្រាស់ មុខងារស្វែងរក ដើម្បីស្វែងរកទីតាំងដែលត្រឹមត្រូវសម្រាប់អ្នក។
   - ប្រសិនបើ អ្នកកំពុងនាំយកកុមារទៅទទួលចាក់ថ្នាំបង្ការ សូមទូរស័ព្ទទៅជាមុនដើម្បីឱ្យប្រាកដថាទីតាំងនោះមានថ្នាំបង្ការដែលត្រឹមត្រូវសម្រាប់កូនរបស់អ្នក និងសាកសួរអំពីការផ្តល់ការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកមើលថែទាំ។
   - ជាការកត់សម្គាល់ ឱសថស្ថានភាគច្រើនមិនអាចចាក់ថ្នាំបង្ការជូនកុមារដែលមានអាយុក្រោម 3 ឆ្នាំទេ។
2. ទូរស័ព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានទាក់ទងនឹងថ្នាំបង្ការ (Vaccine Call Center) តាមរយៈលេខ **(833) 540-0472**។ មជ្ឈមណ្ឌលផ្តល់ព័ត៌មាននេះ បើកបម្រើការជូនជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់។
   - មជ្ឈមណ្ឌលផ្តល់ព័ត៌មាននេះក៏អាចរៀបចំ ការចាក់ថ្នាំបង្ការនៅតាមផ្ទះ និងមធ្យោបាយធ្វើដំណើរដោយឥតគិតថ្លៃបានផងដែរ។
3. ទូរស័ព្ទទៅលេខ **2-1-1** ដែលមានផ្តល់សេវាកម្មជូន 24 ម៉ោងក្នុងមួយថ្ងៃ ពេញមួយសប្តាហ៍ (24/7) និងមានផ្តល់ព័ត៌មានជាភាសាផ្សេងៗជាច្រើន។









**ថ្នាំបង្ការទាំងអស់ដែលមានផ្តល់ជូននៅក្នុងខោនធី LA គឺមានសុវត្ថិភាព និងមានប្រសិទ្ធិភាពក្នុងការទប់ស្កាត់ជំងឺកម្រិតធ្ងន់ធ្ងរ ព្រមទាំងការស្លាប់ដោយសារជំងឺ COVID-19 ផងដែរ។**



- អ្នកដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ អាចទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna ឬក៏ប្រភេទ Novavax បាន។
- អ្នកដែលមានអាយុក្រោម 12 ឆ្នាំអាចទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna បាន។
- ដើម្បីស្វែងយល់បន្ថែមអំពី ភាពមានសិទ្ធិទទួលចាក់ថ្នាំបង្ការបាននិង កាលវិភាគនៃការចាក់ថ្នាំបង្ការ សូមចូលទៅគេហទំព័រ **ph.lacounty.gov/covidvaccineschedules**។

**VaccinateLACounty.com**

COUNTY OF LOS ANGELES Public Health

8/25/22 (Cambodian)